សលាកប័ត្រព័ត៌មាន ៖ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ("ច្បាប់")
ស្ថានភាពបច្ចុប្បន្ន ៖ ច្បាប់នេះត្រូវបានអនុម័តនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
ចំណាត់ថ្នាក់របស់ ម.ស.ម.ក ៖ ពណ៌ក្រហម (ច្បាប់ដែលត្រូវបានចាត់ចំណាត់ថ្នាក់ពណ៌ក្រហមគួរតែត្រូវបានបដិសេធ ចាត់ទុកជាមោឃៈ ឬធ្វើសេចក្តីព្រាងឡើងវិញ)
មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) បានចាត់ចំណាត់ថ្នាក់ពណ៌ក្រហមសម្រាប់ច្បាប់នេះ ។ ច្បាប់នេះបានផ្តល់តួនាទីដែលមានអំណាចលើសលុបឲ្យក្រសួងមហាផ្ទៃ ("ក.ម.ផ") ដែលប៉ះពាល់ដល់បទប្បញ្ញត្តិវិជ្ជមានមួយចំនួន ដោយសារតែតួនាទីរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ("ក្រុមប្រឹក្សា") ក្នុងនាមជាអ្នកតំណាងរបស់ប្រជាពលរដ្ឋមានការលំបាកក្នុងការសម្រុះសម្រួលជាមួយនឹងតួនាទីរបស់ក្រុមប្រឹក្សាដែលជាភ្នាក់ងាររបស់រដ្ឋ ដោយតួនាទីដំបូងគឺតំណាងឲ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយតួនាទីបន្ទាប់តំណាងឲ្យផលប្រយោជន៍របស់រដ្ឋ និងគណបក្សកាន់អំណាច ។ មិជ្ឈការគឺជាវត្ថុបំណងដ៏ប្រពៃមួយ ប្រសិនបើវាផ្ទេរអំណាចទៅឲ្យប្រជាពលរដ្ឋទូទៅ ។ ច្បាប់នេះបរាជ័យបើធៀបទៅនឹងវត្ថុបំណងសំខាន់នេះ ។



សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះ សង្ខេបច្បាប់ដោយសារតែមានការបោះឆ្នោតឃុំសង្កាត់នាពេលថ្មីៗនេះ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ ជាពិសេសពាក់ព័ន្ធនឹងគោលនយោបាយវិមជ្ឈការដែលកាន់តែទូលំទូលាយរបស់រាជរដ្ឋាភិបាលកម្ពុជា ("រ.ដ.ក") ដោយបានលើកឡើងពីការព្រួយបារម្ភ និងអនុសាសន៍មួយចំនួន ។ សលាកប័ត្រនេះតាក់តែងដោយ ម.ស.ម.ក ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ។

សាវតារ ៖ "គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ"

ច្បាប់នេះត្រូវបានអនុម័តជាផ្នែកមួយនៃ "គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ" ដ៏ទូលំទូលាយរបស់រ.ដ.ក ដែលបានបញ្ជាក់ពីគោលដៅពង្រឹងអភិបាលកិច្ចនៅថ្នាក់មូលដ្ឋាន និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យក្នុងប្រទេសកម្ពុជា (មាត្រា១ និង៣) ។ ប្រទេសកម្ពុជាត្រូវបានរៀបចំឡើងជារដ្ឋរួមមួយដែលមានថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិចំនួនបី ដែលឃុំ ឬ "សង្កាត់" (ដូចដែលគេស្គាល់ក្នុងរាជធានី និងក្រុងផ្សេងទៀត) គឺជាថ្នាក់រដ្ឋបាលក្រោមគេបង្អស់ ។ គោលនយោបាយនេះមានគោលបំណងឆ្ពោះទៅរកប្រព័ន្ធគ្រប់គ្រងដែលមានតម្លាភាព និងគណនេយ្យភាព និងកាន់តែមានប្រសិទ្ធិភាព យោងតាមរដ្ឋបាលសាធារណៈ និងសេវាចែកចាយ ដើម្បីកាត់បន្ថយភាពក្រីក្រ និងបង្កើនការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន ។ គោលនយោបាយនេះផ្ទេរអំណាច និងទំនួលខុសត្រូវពីក្រសួង និងស្ថាប័នរដ្ឋ ទៅកាន់អង្គភាពថ្នាក់ក្រោមជាតិ ដែលបន្ទាប់មកនឹងបំពេញតួនាទីជាភ្នាក់ងាររបស់រដ្ឋ ។

សេចក្តីសង្ខេបនៃច្បាប់

ច្បាប់នេះត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ និងត្រូវបានបំពេញបន្ថែមដោយអនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំសង្កាត់ ("អនុក្រឹត្យ") ដែលត្រូវបានអនុម័តនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ។ ច្បាប់នេះចែងអំពីនីតិវិធីគ្រប់គ្រងឃុំសង្កាត់ក្នុងប្រទេសកម្ពុជា ។ ក្រុមប្រឹក្សាឃុំសង្កាត់មួយរូប ("ក្រុមប្រឹក្សា") ត្រូវបានជ្រើសរើសដោយផ្ទាល់តាមរយៈប្រព័ន្ធតំណាងសមាមាត្រ សម្រាប់រយៈពេលប្រាំឆ្នាំដោយប្រជាពលរដ្ឋក្នុងឃុំសង្កាត់ ។ តួនាទីរបស់ក្រុមប្រឹក្សាឃុំសង្កាត់គឺតំណាងឲ្យប្រជាពលរដ្ឋ និងបម្រើផលប្រយោជន៍ឃុំសង្កាត់ ។ ក្រុមប្រឹក្សាមួយមានសមាជិកពីប្រាំទៅដប់មួយរូប អាស្រ័យលើទំហំភូមិសាស្ត្រ និងប្រជាសាស្ត្រនៃឃុំសង្កាត់ (មាត្រា៩ដល់១២ និង១៥) ។ ក្រុមប្រឹក្សាដែលទទួលបន្ទុក និងជាមេឃុំ គឺជាបេក្ខជនដែលស្ថិតនៅក្នុងលេខរៀងខ្ពស់បំផុត ដែលមកពីគណបក្សដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេនៅក្នុងឃុំ ។ គាត់ទទួលបន្ទុកក្នុងការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សា អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា បង្ហាញរបាយការណ៍ការងារប្រចាំខែ និងផ្តល់អនុសាសន៍ទៅកាន់ក្រុមប្រឹក្សា ។ ដើម្បីផ្តល់ជាជំនួយដល់មេឃុំ ជំទប់ចំនួនពីរនាក់ទៀតត្រូវបានជ្រើសរើស ដែលជាបេក្ខជនស្ថិតក្នុងលេខរៀងខ្ពស់ជាងគេ មកពីគណបក្សដែលមានសំឡេងឆ្នោតច្រើនជាងគេទីពីរ និងទីបីនៅក្នុងឃុំ (មាត្រា ១២ ៣២ដល់៣៥ និង៣៩) ។ ឃុំសង្កាត់នីមួយៗមានស្មៀន ដែលត្រូវបានតែងតាំង និងជ្រើសរើសឲ្យបម្រើការងារដោយ ក.ម.ផ ដើម្បីផ្តល់ជា

ជំនួយ និងផ្តល់ដំបូន្មានដល់ក្រុមប្រឹក្សា (មាត្រា២៨) ។ ជាងនេះទៅទៀត ក្រុមប្រឹក្សាជ្រើសរើសមេភូមិមួយរូបសម្រាប់ភូមិនីមួយៗក្នុងឃុំសង្កាត់ (មាត្រា៣០) ។

ដើម្បីឲ្យក្រុមប្រឹក្សាអាចបំពេញមុខងាររបស់ខ្លួន ច្បាប់ត្រូវផ្តល់ឲ្យក្រុមប្រឹក្សានូវអំណាចនីតិបញ្ញត្តិ និងនីតិប្រតិបត្តិជាក់លាក់ (មាត្រា៥ និង៤៨ ដល់៤៩) ។ ក្រុមប្រឹក្សាត្រូវបំពេញកាតព្វកិច្ចពីរប្រភេទ ៖ ទីមួយគឺដោះស្រាយបញ្ហាក្នុងមូលដ្ឋាន ដោយបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងទីពីរគឺបំពេញមុខងាររបស់ភ្នាក់ងារដែលរដ្ឋកំណត់ឲ្យ ។ តួនាទីទីមួយនេះពាក់ព័ន្ធនឹងការរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ផ្តល់សេវាកម្មសាធារណៈ លើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម និងការពារបរិស្ថាន និងធនធានធម្មជាតិ ។ ចំពោះតួនាទីទីពីរ ក្រុមប្រឹក្សាមានអំណាច និងទំនួលខុសត្រូវដែលក្រសួង ឬស្ថាប័នដដ្ឋផ្តល់ឲ្យ ដើម្បីបំពេញកិច្ចការ និងផ្តល់សេវាកម្មជាក់លាក់ ដែលរដ្ឋាភិបាលកណ្តាលបានកំណត់ ។ កិច្ចព្រមព្រៀងនីមួយៗរវាងក្រុមប្រឹក្សា និងស្ថាប័នក្រសួង រដ្ឋាភិបាល និងអន្តរជាតិ ត្រូវមានការឯកភាពពីគណៈកម្មាធិការជាតិគាំទ្រក្រុមប្រឹក្សាឃុំសង្កាត់ និង ក.ម.ផ (មាត្រា៤២ ដល់៤៤ និងមាត្រាអនុក្រឹត្យ៥៥ និង៥៨) ។ ក.ម.ផ ជាអ្នកត្រួតពិនិត្យការងាររបស់ក្រុមប្រឹក្សា ដែលមានសិទ្ធិធ្វើអន្តរគមន៍ប្រសិនបើក្រុមប្រឹក្សាមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលច្បាប់បានកំណត់ (មាត្រា៥៣ ដល់៥៧) ។

ការព្រួយបារម្ភ និងអនុសាសន៍

ច្បាប់នេះមានបទប្បញ្ញត្តិវិជ្ជមានមួយចំនួនដែលមានគោលបំណងបង្កើនតម្លាភាព និងលំហូរនៃព័ត៌មានពាក់ព័ន្ធនឹងការងាររបស់ក្រុមប្រឹក្សា ឧទាហរណ៍តាមរយៈការប្រើប្រាស់ក្តារព័ត៌មានសាធារណៈដែលជាកតាព្វកិច្ច និងសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានឯកសារ (មាត្រាអនុក្រឹត្យ ៧ និង១០) ។ ជាងនេះទៅទៀត មានភស្តុតាងបង្ហាញថាច្បាប់នេះបានចែងអំពីគណនេយ្យភាពកាន់តែប្រសើរ និងគាំទ្របន្ថែមទៀតនូវអភិបាលកិច្ចនៃការចូលរួម និងអភិបាលកិច្ចក្នុងប្រទេសដូចជាសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាប្រចាំខែ ផ្តល់ជាយោបល់ ឬដាក់បណ្តឹងទៅកាន់ក្រុមប្រឹក្សា (មាត្រា២១ និង២៣ មាត្រាអនុក្រឹត្យ៣០ ដល់៣១) ។ ទោះបីជាយ៉ាងណាក៏ដោយ ម.ស.ម.ក នៅតែមានការព្រួយបារម្ភសំខាន់ៗមួយចំនួន ។

ច្បាប់នេះផ្តល់តួនាទីដែលមានអំណាចគ្រប់គ្រងដល់ ក.ម.ផ ជាមួយនឹងឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយ ដែលបណ្តាលឲ្យការប៉ុនប៉ងដើម្បីបង្កើនវិមជ្ឈការ និងធ្វើវិសហមជ្ឈការអភិបាលកិច្ចបែបប្រជាធិបតេយ្យត្រូវអសាបង់ ។ តាមពិត អំណាចនីតិបញ្ញត្តិរបស់ក្រុមប្រឹក្សាត្រូវបានគេដាក់កម្រិតយ៉ាងធ្ងន់ធ្ងរ ដោយ ក.ម.ផ អាចបោះឆ្នោតបដិសេធចំពោះសេចក្តីសម្រេចទាំងឡាយណាដែល *"ផ្ទុយទៅនឹងស្មារតី"* ដែលមាននៅក្នុងនីតិបញ្ញត្តិជាតិ និងអន្តរជាតិ (មាត្រា៤៩) ។ ក្រុមប្រឹក្សាត្រូវតែសុំការឯកភាពពី ក.ម.ផ ចំពោះទំនាក់ទំនងជាផ្លូវការទាំងឡាយដែលខ្លួនមានបំណងធ្វើឡើងជាមួយនឹង រ.ដ.ក ក្រសួង ឬអង្គការជាតិ និងអន្តរជាតិដទៃទៀត ។ ការផ្ទេរអំណាចទាំងឡាយណាទៅកាន់ក្រុមប្រឹក្សា ត្រូវមានការអនុញ្ញាតពីគណៈកម្មាធិការជាតិគាំទ្រក្រុមប្រឹក្សាឃុំសង្កាត់ ដែលមាន ក.ម.ផ ជាអ្នកដឹកនាំ (មាត្រា៨៧ មាត្រាអនុក្រឹត្យ៤២ និង៥៥ ដល់៥៨) ។ ការបំពេញតួនាទីដែលរដ្ឋផ្ទេរជូនរបស់ក្រុមប្រឹក្សា ត្រូវមានការឃ្លាំមើល និងត្រួតពិនិត្យដោយ ក.ម.ផ ដែលអាចធ្វើអន្តរគមន៍ក្នុងករណីក្រុមប្រឹក្សាខកខានមិនបានបំពេញតួនាទីដោយដកហូតនិងគ្រប់គ្រងតួនាទីដែល ក.ម.ផ ដាក់ឲ្យក្រុប្រឹក្សា ឬសូម្បីតែរំលាយក្រុមប្រឹក្សាទាំងស្រុងតែម្តង (មាត្រា៥៣ ដល់៥៨) ។ ចំពោះការប៉ុនប៉ងនីមួយៗដើម្បីធ្វើវិមជ្ឈការទំនួលខុសត្រូវ នឹងមានកិច្ចខិតខំប្រឹងប្រែងមួយដើម្បីធានាថានឹងមានការត្រួតពិនិត្យយ៉ាងតឹងរឹងពី រ.ដ.ក ។ ម.ស.ម.ក ស្នើឲ្យមានការដាក់កម្រិតលើអំណាចដែលបានផ្តល់ឲ្យ ក.ម.ផ ដើម្បីពង្រឹងអភិបាលកិច្ចបែបវិមជ្ឈការ និងរដ្ឋបាលថ្នាក់មូលដ្ឋានដើម្បីឲ្យវិធានការនីតិបញ្ញត្តិដូចជាច្បាប់អាចធ្វើអ្វីលើសពីការត្រឹមតែមានឈ្មោះថាលើកកម្ពស់ប្រជាធិបតេយ្យ ។

តួនាទីទាំងពីររបស់ក្រុមប្រឹក្សាប៉ះពាល់ដល់វត្ថុបំណងនៃគោលនយោបាយ ។ ក្នុងករណីមួយ អ្នកធ្វើសេចក្តីសម្រេចត្រូវបានធ្វើឲ្យមានទំនួលខុសត្រូវបន្ថែមទៀតចំពោះប្រជាពលរដ្ឋ ប៉ុន្តែមួយវិញទៀត ក្រុមប្រឹក្សាដើរតួនាទីជាភ្នាក់ងាររបស់ក្រសួង និងស្ថាប័ន ។ ដោយតួនាទីទីពីររបស់ក្រុមប្រឹក្សាស្ទើរតែត្រូវបានគ្រប់គ្រងទាំងស្រុងដោយគណបក្សកាន់អំណាច ដូច្នេះធ្វើឲ្យមុខងារជាអ្នកតំណាងរបស់ក្រុមប្រឹក្សាទទួលរងផលប៉ះពាល់ដោយមុខងារជាភ្នាក់ងាររបស់រដ្ឋ ។ ប្រសិនបើក្រុមប្រឹក្សាមិនត្រូវបានផ្តល់អំណាចជាអ្នកតំណាងពិតប្រាកដរបស់ប្រជាពលរដ្ឋទេ ដោយមានត្រឹមតែការត្រួតពិនិត្យបន្តិចបន្តួច និងមានកម្រិតខ្ពស់ពីរដ្ឋ និងក្រសួង នោះវត្ថុបំណងនៃគោលនយោបាយមិនអាចសម្រេចបានឡើយ ។ ក្នុងស្ថានភាពបច្ចុប្បន្ន ច្បាប់នេះប្រតិបត្តិដើម្បីពង្រីកវិសាលភាពរបស់រដ្ឋាភិបាលកណ្តាល ជាជាងការធ្វើវិមជ្ឈការ ដែលនេះប៉ះពាល់ដល់លទ្ធិប្រជាធិបតេយ្យជាជាងការធ្វើវិសហមជ្ឈការប្រជាធិបតេយ្យ ។ ច្បាប់នេះគួរតែត្រូវបានធ្វើវិសោធនកម្មដើម្បីឲ្យមានការលើកកម្ពស់វិមជ្ឈការប្រជាធិបតេយ្យពិតប្រាកដ ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង លោក អ៊ូ រិះ: (+៨៥៥ (0) ១២ ៤០ ៤០ ៥១ ឬអ៊ីម៉ែល៖ ouvirak@cchrcambodia.org **ឬ លោក រ៉ូប៊ឺត ហ្វីនច៍ (+៨៥៥ (0) ៧៨ ៨0 ៩៩ ៦0) ឬអ៊ីម៉ែល** robert.finch@cchrcambodia.org

ម.ស.ម.ក ធ្វើចំណាត់ថ្នាក់ច្បាប់នីមួយៗ ដោយផ្អែកលើភាពអាចទទួលយកបាន និងភាពអនុលោមតាមរដ្ឋធម្មនុញ្ញ និងកាតព្វកិច្ចរបស់កម្ពុជាតាមរយៈ:ច្បាប់ជាតិ និងអន្តរជាតិ ព្រមទាំងភាពជាក់លាក់នៃបទប្បញ្ញត្តិ ។ ច្បាប់ទាំងឡាយណា ដែលត្រូវបានធ្វើចំណាត់ពណ៌បៃតង គឺមានន័យថា អាចទទួលយកបានតាមទស្សនៈរបស់ ម.ស.ម.ក ។ ច្បាប់ដែលត្រូវបានធ្វើចំណាត់ថ្នាក់ពណ៌លឿង គឺផ្ទុកនូវការព្រួយបារម្ភមួយចំនួន ដែលត្រូវតែធ្វើការត្រួតពិនិត្យឡើងវិញ និងត្រូវតែធ្វើវិសោធនកម្ម ។ ដោយឡែកច្បាប់ដែលមានចំណាត់ថ្នាក់ពណ៌ក្រហម គឺជាច្បាប់ដែលមានលក្ខណៈធ្ងន់ធ្ងរជ្រុលហួសហេតុ និង/ឬរំលោភរដ្ឋធម្មនុញ្ញ និង/ឬកាតព្វកិច្ចរបស់កម្ពុជាតាមរយៈ:ច្បាប់អន្តរជាតិ និងច្បាប់ជាតិ ហើយដូច្នេះត្រូវតែបដិសេធ ទុកជាមោឃៈ ឬតាក់តែងជាថ្មីឲ្យបានសមស្រប ។